# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
CAMBODIA WATCHDOG COUNCIL INTERNATIONAL

ក្រុងគ្រីស្ទានសាន់ (ន័រវេស៍) ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩

## សេចក្តីថ្លែងការណ៍
## ត្រូវដោះលែងយុវជន គង់ រ៉ៃយ៉ា និង សួង នាគព័ន្ធ ដោយគ្មានលក្ខខណ្ឌ ហើយត្រូវទម្លាក់ចោលការភ្ជាប់សំណុំរឿង ទៅនឹងគណបក្សប្រឆាំង

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា និត្យឃើញថាលោក គង់ រ៉ៃយ៉ា និងលោក សួង នាគព័ន្ធ គ្មានកំហុសដូចការចោទប្រកាន់របស់តុលាការភ្នំពេញ និងរដ្ឋាភិបាលលោក ហ៊ុន សែន ទេ។ ការចាប់ឃុំខ្លួនអ្នកទាំងពីរ ជាអំពើអយុត្តិធម៌ និងជាការរំលោភរដ្ឋធម្មនុញ្ញយ៉ាងធ្ងន់ធ្ងរ។

លោក គង់ រ៉ៃយ៉ា និងលោក សួង នាគព័ន្ធ មានសិទ្ធិបញ្ចេញមតិពេញលេញក្នុងនាមជាពលរដ្ឋខ្មែរ ដែលកំណត់ដោយរដ្ឋធម្មនុញ្ញ ដូចមានចែងក្នុងជំពូក ៣ ស្តីអំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ នៅមាត្រា៤១ កថាខណ្ឌទី១ បានចែងថា *«ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ»*។

ដូចកថាខណ្ឌខាងលើ ការបញ្ចេញមតិរបស់លោក សួង នាគព័ន្ធ និងផ្សព្វផ្សាយលក់អាវយឺតរូបលោកបណ្ឌិត កែម ឡី របស់លោក គង់ រ៉ៃយ៉ា ក្នុងពិធីបុណ្យរំលឹកខួបគម្រប់ ៣ ឆ្នាំបណ្ឌិត កែម ឡី គឺគ្មានអ្វីខុសទាស់ទេ។ ទង្វើរបស់អ្នកទាំងពីរ បានប្រព្រឹត្តទៅក្នុងជីវភាពរស់នៅជាធម្មតា ដូចពលរដ្ឋខ្មែរដទៃទៀតដែរ ក្នុងការនិយាយស្តី ការបញ្ចេញមតិ ការជួបប្រជុំ ការចូលរួមក្នុងពិធីបុណ្យខួប និងពិធីប្រពៃណីវប្បធម៌សាសនា (មាត្រា ៤៣ កថាខណ្ឌទី១ *«ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ»*)។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា យល់ឃើញថា រដ្ឋាភិបាលលោក ហ៊ុន សែន ពុំត្រូវភ្ជាប់សំណុំរឿងឃុំខ្លួនអ្នកទាំងពីរ ទៅនឹងសកម្មភាពបង្កចលាចល ឬសកម្មភាពឧក្រិដ្ឋណាមួយ ជាមួយគណបក្សប្រឆាំង (គណបក្សសង្គ្រោះជាតិ) ដែលតុលាការកំពូលបានរំលាយចោល កាលពីឆ្នាំ២០១៧ យ៉ាងអយុត្តិធម៌ និងទាំងបំពានរដ្ឋធម្មនុញ្ញដែរនោះទេ។ វាជារឿងដោយឡែកពីគ្នា ពោលគឺលោក គង់ រ៉ៃយ៉ា និងលោក សួង នាគព័ន្ធ សុទ្ធតែជាអ្នកមានភក្តីភាពចំពោះបណ្ឌិត កែម ឡី ក្នុងនាមជាសិស្ស និងគ្រូ ហើយពួកគេ មានបំណងចង់សងគុណ និង រំលឹកគុណគ្រូរបស់ពួកគេតែប៉ុណ្ណោះ ក្នុងពិធីបុណ្យខួបគម្រប់ ៣ ឆ្នាំ ដែលត្រូវបានគេធ្វើឃាតយ៉ាងអយុត្តិធម៌។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមអំពាវនាវដល់រដ្ឋាភិបាល និងតុលាការរបស់លោក ហ៊ុន សែន ត្រូវតែទម្លាក់ចោលសំណុំរឿងចោទប្រកាន់លោក គង់ រ៉ៃយ៉ា និងលោក សួង នាគព័ន្ធ ព្រមទាំងដោះលែងទាំងពីរដោយគ្មានលក្ខខណ្ឌ ហើយវិលមកស្តារស្ថានភាពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងរក្សាបាននូវប្រព័ន្ធអនុគ្រោះពន្ធនានារបស់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ដែលជាក្តីព្រួយបារម្ភធំបំផុតរបស់ខ្មែរយើងទាំងអស់គ្នា។

**ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ម៉ែន ណាត**

Address: Senterveien 54, Apartment 112, 4790 Lillesand, NORWAY /Contact nathamonin@gmail.com /Hompage: https://cwcicambodia.net